ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៧ លេខ ៦៨ ត្រីមាសទី ០៣ ឆ្នាំ ២០១៧

រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៤-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦០០ ស្តីពី ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិជូនអ្នករាជការ គ.ជ.ប ចំនួន ១៧ រូប នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ៧១៦០

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៤១ ស្តីពី ការផ្ទេរក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលត្រូវបានបង្កើតដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ដោយផ្ទេរសមាហរណកម្មការងារ និងរចនាសម្ព័ន្ធទាំងឡាយ រួមមាន ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ចលនទ្រព្យ អចលនទ្រព្យ ។ ល ។ របស់ក្រុមប្រឹក្សានេះ ដែលកន្លងមក ឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា ៧១៦២

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៤២ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តមបណ្ឌិត **នៅ ស៊ុន** ជាប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ជំនួសឯកឧត្តមបណ្ឌិតសភាចារ្យ **ចន្ទ សំណព្វ** ដែលត្រូវទទួលភារកិច្ចថ្មី ៧១៦៤

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៤៣ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន** ជាទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា ទទួលបន្ទុកជាអនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ៧១៦៦

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៤៤ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ជាទីប្រឹក្សានៃវេទិកាសម្ព័ន្ធសង្គមស៊ីវិល (វ.ស.ស.) ចំនួន ០៤ រូប ៧១៦៨

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៤៥ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ជាអគ្គលេខាធិការ និងអគ្គលេខាធិការរង នៃវេទិកាសម្ព័ន្ធសង្គមស៊ីវិល ចំនួន ០៤ រូប ៧១៦៩

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៤៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ដល់មន្ត្រីរាជការចំនួន ០៣ រូប ជាទីប្រឹក្សាក្រសួងពាណិជ្ជកម្ម មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៧១៧០

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៤៧ ស្តីពី ការតែងតាំង និងផ្តល់ឋានៈដល់មន្ត្រីរាជការចំនួន ០២ រូប ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក ៧១៧១

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៤៨ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈឯកឧត្តម **សារិន រ៉ាត់ណាត់ដាណៃ** ជាទីប្រឹក្សាសម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយពុំទទួលយកប្រាក់បៀវត្ស ៧១៧២

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៤៩ ស្ដីពី ការផ្ដល់ឋានៈជូនអនុប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាលនៃវេទិកាសម្ព័ន្ធសង្គមស៊ីវិល (វ.ស.ស.) ចំនួន ០៦ រូប ៧១៧៣

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៥១ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ជូនឧត្តមសេនីយ៍ត្រី **ហេង ចំរើន** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៧១៧៤

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៥២ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ជូនឧត្តមសេនីយ៍ត្រី **សុខ សំណាង** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៧១៧៥

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៥៣ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ជូនវរសេនីយ៍ឯក **និត្យ ណារ៉ុង** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៧១៧៦

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៥៤ ស្ដីពី ការតម្លើងថ្នាក់ដល់លោក **ប៉ែន សំអាត** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៧១៧៧

២៨-០៨-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៨១៧/៦៥៥ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ជូនវរសេនីយ៍ឯក **កើត ដារ៉ាស៊ី** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៧១៧៨

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

២៥-០៨-២០១៧ -អនុក្រឹត្យលេខ ១៣៩ អនក្រ.បក ស្ដីពី ការធ្វើអនុបយោគ ប្ដូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៧១៧៩

២៦-០៨-២០១៧ -អនុក្រឹត្យលេខ ១៤០ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ៧ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ ស្តីពី ការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃ ច្បាប់ ស្តីពី ការងារ ៧១៨១

២៨-០៨-២០១៧ -អនុក្រឹត្យលេខ ១៤១ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ៣០ ជំពូកទី ៣ នៃអនុក្រឹត្យលេខ ១៩៩ អនក្រ.បក ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ ស្តីពី បែបបទនៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍ ៧១៨៤

២៥-០៨-២០១៧ -អនុក្រឹត្យលេខ ៩៦៩ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ៧១៨៧

២៥-០៨-២០១៧ -អនុក្រឹត្យលេខ ៩៧០ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧១៨៨

២៥-០៨-២០១៧ -អនុក្រឹត្យលេខ ៩៧១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧១៨៩

២៥-០៨-២០១៧ -អនុក្រឹត្យលេខ ៩៧២ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ៧១៩០

២៥-០៨-២០១៧ -អនុក្រឹត្យលេខ ៩៧៣ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៧១៩៤

២៨-០៨-២០១៧ -អនុក្រឹត្យលេខ ៩៧៤ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិ ៧២០២

២៨-០៨-២០១៧ -អនុក្រឹត្យលេខ ៩៧៥ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ៧២០៣

២៨-០៨-២០១៧ -អនុក្រឹត្យលេខ ៩៧៦ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៧២០៤

២៨-០៨-២០១៧ -អនុក្រឹត្យលេខ ៩៧៧ អនក្រ.តត ស្តីពី ការផ្ទេរយោធិនពលី ៧២០៥

២៨-០៨-២០១៧ -អនុក្រឹត្យលេខ ៩៧៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧២០៧

២៨-០៨-២០១៧ -អនុក្រឹត្យលេខ ៩៧៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧២០៨

២៩-០៨-២០១៧ -អនុក្រឹត្យលេខ ៩៨០ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាន់ខ្ពស់ ៧២១០

២៩-០៨-២០១៧ -អនុក្រឹត្យលេខ ៩៨១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៧២១១

២៩-០៨-២០១៧ -អនុក្រឹត្យលេខ ៩៨២ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៧២១២

២៩-០៨-២០១៧ -អនុក្រឹត្យលេខ ៩៨៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧២១៣

២៩-០៨-២០១៧ -អនុក្រឹត្យលេខ ៩៨៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧២១៤

២៩-០៨-២០១៧ -អនុក្រឹត្យលេខ ៩៨៥ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៧២១៥

២៩-០៨-២០១៧ -អនុក្រឹត្យលេខ ៩៨៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧២១៦

២៩-០៨-២០១៧ -អនុក្រឹត្យលេខ ៩៨៧ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ៧២១៧

២៩-០៨-២០១៧ -អនុក្រឹត្យលេខ ៩៨៨ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៧២១៨

២៩-០៨-២០១៧ -អនុក្រឹត្យលេខ ៩៨៩ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៧២២០

២.សេចក្តីសម្រេច

០១-០៩-២០១៧ -សេចក្តីសម្រេចលេខ ៧៤ សសរ ស្តីពី ការបង្កើតក្រុមការងារស្រាវជ្រាវផ្តល់យោបល់ផ្នែកអភិបាលកិច្ចសន្តិសុខ ៧២២១

០៤-០៩-២០១៧ -សេចក្តីសម្រេចលេខ ៧៥ សសរ ស្តីពី ការបង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នា លើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា នៃខ្ពង់រាបបាតសមុទ្រ កម្ពុជា-ថៃ ៧២២៣

III.ការងារបណ្តាក្រសួង

១.ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៦-១២-២០១៦ -ប្រកាសលេខ ១៥៥២ សហវ.ប្រក ស្តីពី ការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ *(តមកពី រាជកិច្ចលេខ ៦៧)* ៧២២៦

២៦-១២-២០១៦ -ប្រកាសលេខ ១៥៥៤ សហវ.ប្រក ស្តីពី ការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី នៃមាតិកាថវិកា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ *(តមកពី រាជកិច្ចលេខ ៦៧)* ៧២២៨

២.ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

០៨-០៦-២០១៧ -ប្រកាសលេខ ២៤៣ ឧស.កឧ.ប្រក ០៦ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ុយ យ៉ាត អេ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ ៧២៩៧

ព្រះរាជក្រឹត្យ

នស/រកត/០៤១៧/៦០០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែកនៃក្រមខ័ណ្ឌមន្ត្រីរាជការ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានដំឡើងថ្នាក់ជូនអ្នករាជការ គ.ជ.ប ចំនួន **០៩ រូប** ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៧ ដូចមានរាយនាមខាងក្រោម ៖

ល.រ	គោត្តនាម និងនាម	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ឋានន្តរស័ក្តិ និងថ្នាក់ថ្មី
១	ឯកឧត្តម **សោម សូរីដា**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៣	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ២
២	ឯកឧត្តម **សំ សាឌុន**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៣	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ២

៣	ឯកឧត្តម **កុសុល: ធីរ៉ោ**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៣	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ២
៤	ឯកឧត្តម **កែវ ផល្លា**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៣	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ២
៥	ឯកឧត្តម **កែ រិទ្ធិ**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៣	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ២
៦	ឯកឧត្តម **ឆាយ សុផាន់ណា**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៥	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៤
៧	ឯកឧត្តម **ហ៊ី រ៉ុឌ**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៦	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៥
៨	ឯកឧត្តម **សយ សាខន**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៦	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៥
៩	ឯកឧត្តម **យឿង កុសល**	ពីឧត្តមមន្ត្រីថ្នាក់លេខ ៦	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៥

មាត្រា២ : ត្រូវបានដំឡើងឋានន្តរស័ក្តិជូនអ្នករាជការ គ.ជ.ប ចំនួន **០៨ រូប** ទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៧ ដូចមានរាយនាមខាងក្រោម ៖

ល.រ	**គោត្តនាម និងនាម**	**ឋានន្តរស័ក្តិ និងថ្នាក់ចាស់**	**ឋានន្តរស័ក្តិ និងថ្នាក់ថ្មី**
១	ឯកឧត្តម **ជិញ សំភួ**	ពីវរមន្ត្រីថ្នាក់លេខ ១	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៦
២	ឯកឧត្តម **ខន កែវមនោ**	ពីវរមន្ត្រីថ្នាក់លេខ ១	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៦
៣	ឯកឧត្តម **តុប ឫទ្ធី**	ពីវរមន្ត្រីថ្នាក់លេខ ១	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៦
៤	លោកជំទាវ **ម៉ុន សុភី**	ពីវរមន្ត្រីថ្នាក់លេខ ១	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៦
៥	ឯកឧត្តម **គង់ សំអាត**	ពីវរមន្ត្រីថ្នាក់លេខ ១	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៦
៦	ឯកឧត្តម **តាន់ ម៉ុនធីរ:**	ពីវរមន្ត្រីថ្នាក់លេខ ១	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៦
៧	ឯកឧត្តម **ធី បណ្ឌាល**	ពីវរមន្ត្រីថ្នាក់លេខ ១	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៦
៨	ឯកឧត្តម **តែ ជិនណារិទ្ធ**	ពីវរមន្ត្រីថ្នាក់លេខ ១	ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ៦

មាត្រា៣ : ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាបន្ទាប់

ប្រមុខរដ្ឋស្តីទី

នរ.ក. ១៧០៧.៦០៧

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លេខ: ៦៤៤ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ,ថ្ងៃទី៣១ ខែ សីហា ឆ្នាំ២០១៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៨៤១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្មូហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី, មាត្រា១០ថ្មី, មាត្រា១១ថ្មី, មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០, មាត្រា១១, មាត្រា១២, មាត្រា១៤, មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ត្រាស់បង្គាប់

មាត្រា១.-

ត្រូវបានផ្ទេរក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលត្រូវបានបង្កើតដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ដោយធ្វើសមាហរណកម្មការងារ និងរចនាសម្ព័ន្ធទាំងឡាយ រួមមាន ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ចលនទ្រព្យ អចលនទ្រព្យ ។ល។ របស់ក្រុមប្រឹក្សានេះ ដែលមានកន្លងមក ឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា។

មាត្រា២.-

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៣.-

សមាភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលត្រូវបានតែងតាំងមុនថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ត្រូវទុកជាមោឃៈ។

មាត្រា៤.-

ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៥.-

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

[illegible].១៧០៨.៦៤០

លេខៈ ៦៤៥ ស.ណ

សំណៅដែលមានតម្លៃជាភ្នាក់ងារចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦៤២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពី ការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី, មាត្រា១០ថ្មី, មាត្រា១១ថ្មី, មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០, មាត្រា១១, មាត្រា១២, មាត្រា១៤, មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ព្រះរាជក្រឹត្យ... ត្រាស់បង្គាប់

មាត្រា១.- តែងតាំងនិងផ្ដល់ឋានៈឯកឧត្តមបណ្ឌិត **នៅ ស៊ីន** ជាប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ មានឋានៈស្មើអនុរដ្ឋលេខាធិការ ជំនួសឯកឧត្តមបណ្ឌិតសភាចារ្យ **ច័ន្ទ សំណាញ** ដែលត្រូវទទួលភារកិច្ចថ្មី។

មាត្រា២.- បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣.- សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

នស/រកត.០៨១៧.៦៥១

សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ

លេខៈ ៦៤៦ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦៤៣

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពី ការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី, មាត្រា១០ថ្មី, មាត្រា១១ថ្មី, មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា១០, មាត្រា១១, មាត្រា១២, មាត្រា១៤, មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៥៩២ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះចៅមហាក្សត្រ

ត្រាស់បង្គាប់

មាត្រា១.- តែងតាំង និងផ្តល់ឋានៈឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន** ជាទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា ទទួលបន្ទុកជាអនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ។

មាត្រា២.- បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣.- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

នស.រកត.០៨១៧.៦៥៤

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លេខៈ ៦៤៧ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦៤៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សានៃវេទិកាសម្ព័ន្ធសង្គមស៊ីវិល (វ.ស.ស.) ចំនួន ០៤ រូប ដូចខាងក្រោម :

១- ឯកឧត្តម **អ៊ឹម មល្លិវណ្ណ** ជាទីប្រឹក្សានៃ វ.ស.ស. មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
២- ឯកឧត្តម **ឈាង វណ្ណារិទ្ធ** ជាទីប្រឹក្សានៃ វ.ស.ស. មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**
៣- ឯកឧត្តម **ឆែ សុខន** ជាទីប្រឹក្សានៃ វ.ស.ស. មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
៤- ឯកឧត្តម **ស៊ុន បញ្ញា** ជាទីប្រឹក្សានៃ វ.ស.ស. មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

៣៧៣.១៧០៨.៦៥៣

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លេខៈ ៦៤៩ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំង និងផ្តល់ឋានៈជាអគ្គលេខាធិការ និងអគ្គលេខាធិការរងនៃវេទិកាសម្ព័ន្ធសង្គមស៊ីវិល ចំនួន ០៤ រូប ដូចខាងក្រោម :

១- ឯកឧត្តម	**ប៉ៃ សិប្ហូរ**	ជាអគ្គលេខាធិការ មានឋានៈស្មើ **រដ្ឋលេខាធិការ**
២- ឯកឧត្តម	**សេដ្ឋា ចន្ទ្រានា**	ជាអគ្គលេខាធិការរង មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
៣- ឯកឧត្តម	**ប្រាក់ ផាន់ណារ៉ា**	ជាអគ្គលេខាធិការរង មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
៤- ឯកឧត្តម	**អេង ភុកថាយ**	ជាអគ្គលេខាធិការរង មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

៣៧៧.១៧០៨.៦៥៤

លេខ: ៦៤៩ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦៤៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូន ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំង និងផ្តល់ឋានៈដល់មន្ត្រីរាជការ ចំនួន ០៣ រូប ជាទីប្រឹក្សាក្រសួងពាណិជ្ជកម្ម មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **គឹម មាសសុខសីហា**
២- ឯកឧត្តម **ស៊ុំ ណារុន**
៣- ឯកឧត្តម **ឈឿង រដ្ឋា** ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

៧៧.១៧០៨.៦៥៥

លេខ: ៦៤៣ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦៤៧ **យើង**

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំង និងផ្តល់ឋានៈដល់មន្ត្រីរាជការ ចំនួន ០២ រូប ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ **អគ្គនាយក** ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ឯក ថា**
២- ឯកឧត្តម **មាស ហ៊ីត** ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៧
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

៣៧.១៧០៨.៦៥៦

ហត្ថលេខា និងព្រះរាជលញ្ចករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លេខ: ៦៥២ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំង និងផ្តល់ឋានៈឯកឧត្តម **សារិន រ៉ាត់ណាត់ដារ៉ែណ** ជាទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលយកប្រាក់បៀវត្ស ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

៧.៧.១៧០៨-៦៤៧

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លេខៈ ៦៥០ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់ឋានៈជូនអនុប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាលនៃវេទិកាសម្ព័ន្ធសង្គមស៊ីវិល (វ.ស.ស.) ចំនួន ០៦ រូប ដូចខាងក្រោម :

១- ឯកឧត្តម **ដួង ទីរិទ្ធ** អនុប្រធានក្រុមប្រឹក្សាភិបាល មានឋានៈស្មើ **រដ្ឋលេខាធិការ**
២- ឯកឧត្តម **សោម អូន** អនុប្រធានក្រុមប្រឹក្សាភិបាល មានឋានៈស្មើ **រដ្ឋលេខាធិការ**
៣- ឯកឧត្តម **ម៉ិន ត្រាឈៃ** សមាជិកក្រុមប្រឹក្សាភិបាល មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**
៤- ឯកឧត្តម **គ្រី ជីវ័ន** សមាជិកក្រុមប្រឹក្សាភិបាល មានឋានៈស្មើ **អគ្គនាយក**
៥- ឯកឧត្តម **នាក់ ចិន្តារិទ្ធិ** សមាជិកក្រុមប្រឹក្សាភិបាល មានឋានៈស្មើ **អគ្គនាយក**
៦- លោកជំទាវ **អ៊ុង ច័ន្ទសោភា** សមាជិកាក្រុមប្រឹក្សាភិបាល មានឋានៈស្មើ **អគ្គនាយក** ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

៣៧.១៧០៨.៦៤៧

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លេខ: ៦៥១ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦៥១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** ជូនឧត្តមសេនីយ៍ត្រី **ហេង ចំរើន** អត្តលេខ **៥៤៨៦១** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

៣៧.១៧០៨.៦៦០

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លេខៈ ៦៥៣ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** ជូនឧត្តមសេនីយ៍ត្រី **សុខ សំណាង** អត្តលេខ **០២១២១** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

៣៧.១៧០៨.៦៦១

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លេខៈ ៦៥៤ ស.ណ

សំណៅដែលមានតម្លៃជាភ្នាក់បែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦៥៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ជូនវរសេនីយ៍ឯក **ឌិត្យ ណារ៉ុង** អត្តលេខ ០៨០៤៨ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

៣៧៧.១៧០៧.៦៦២

លេខ: ៦៥៥ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦៥៤

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ដំឡើងថ្នាក់ដល់លោក **ម៉ែន សំអាត** ពីឋានន្តរស័ក្តិ **ឧត្តមមន្ត្រី** ថ្នាក់លេខ **២** មកឋានន្តរស័ក្តិ **ឧត្តមមន្ត្រី** ថ្នាក់លេខ **១** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា២ : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្ដីទី

ពរម.១៧០៨.៦៦៣

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ

លេខៈ៦៥៦ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១៧/៦៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ជូនវរសេនីយ៍ឯក **កើត ជាវ៉ាស៊ី** អត្តលេខ **០៨៩៥៩** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៧

គូលព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

៣៧. ១៧០៨. ៦៦៤

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លេខ: ៦៥៧ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១៣៩...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩១៣ /៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១២១៣ /១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការប្រែប្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០៦ /៣៣៩ ចុះថ្ងៃទី០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ៤១៧ សជណ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៩៦៣ សជណ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៤០២ សជណ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៩០០ សជណ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ៨៥០ លស ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ របស់ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ :-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំងដូចខាងក្រោម÷

-ដីទំនេររបស់មន្ទីររ៉ែ និងថាមពល ខេត្តពោធិ៍សាត់ ស្ថិតនៅភូមិស្ថានីយ៍ សង្កាត់ស្វាយអាត់ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ មានទំហំដី ១.២៤៤ ម៉ែត្រក្រឡា។

-ដីទំនេរចំនួន ០២កន្លែងរបស់សាលាស្រុកអង្គរជ័យ ខេត្តកំពត ទីតាំងទីមួយដីទំហំ ២.១៦៣ ម៉ែត្រក្រឡា ស្ថិតនៅតាមបណ្តោយ ផ្លូវជាតិលេខ ៣១ ភូមិពោធិ៍ ឃុំភ្នំកុង ខេត្តកំពត ទីតាំងដីមានទំហំ ១.០៥០ ម៉ែត្រក្រឡា ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ១២៦ ភូមិប្រាល ឃុំតានី ស្រុកអង្គជ័យ ខេត្តកំពត និងដីនៅសល់ផ្នែកខាងក្រោយទំហំ ១.០៧៣ ម៉ែត្រក្រឡា។

-ពន្ធនាគារខេត្តពោធិ៍សាត់ របស់ក្រសួងមហាផ្ទៃ ស្ថិតនៅភូមិចំការចេកខាងជើង ឃុំផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ មានទំហំដី ១០.០៣៩ ម៉ែត្រក្រឡា។

-អតីតផ្ទះសំណាក់ព្រាបស របស់ក្រសួងពាណិជ្ជកម្ម ស្ថិតនៅដីឡូតិ៍លេខ៧៧ ផ្លូវលេខ២៤០ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានទំហំដី ៥១៨,៦៨ ម៉ែត្រក្រឡា។

មាត្រា ២ :-

-ការលុបទីតាំងដូចមានចែងក្នុងមាត្រា១ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធី ដោយក្រសួងមហាផ្ទៃ ក្រសួងរ៉ែ និងថាមពល និងក្រសួងពាណិជ្ជកម្ម។

មាត្រា ៣ :-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៤ :-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលមាត្រា ៧ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រាមួយ .-

ត្រូវបានកែសម្រួលមាត្រា ៧ នៃអនុក្រឹត្យលេខ ០១ អនក្រ. បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

មាត្រា ៧ ថ្មី .-

និយោជក និងកម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាព ជូនដល់ ប.ស.ស ហួតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។

កាតព្វកិច្ចនៃការបង់ភាគទានផ្នែកថែទាំសុខភាពដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ត្រូវស្ថិតនៅក្នុងបន្ទុកទាំងស្រុងរបស់និយោជក ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ។

មាត្រាពីរ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីបទប្បញ្ញត្តិនៃអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រាបី .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..១៤១...អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលមាត្រា៣០ជំពូកទី៣នៃអនុក្រឹត្យលេខ ១៩៩ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្តីពីបែបបទនៃការទទួលសិទ្ធិនិងការគណនាប្រាក់បំណាច់ពិការភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
